សម្រាប់ការចេញផ្សាយបន្ទាន់
ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៦

សេចក្តីប្រកាសព័ត៌មាន

# ដែនជម្រកសត្វព្រៃកែវសីមា បានលក់ឥណទានកាបូនដំបូងរបស់ខ្លួន

រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) បាន និងកំពុងការពារព្រៃឈើតំបន់ត្រូពិចដែលមានសារៈសំខាន់ជាសាកល។

**ភ្នំពេញ កម្ពុជា ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦៖** រាជរដ្ឋាភិបាលកម្ពុជា តាមរយៈកិច្ចសហការជាមួយអង្គការ WCS បានលក់ឥណទានកាបូនដំបូងរបស់គម្រោងកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងដែនជម្រកសត្វព្រៃកែវសីមាដែលមានទំហំព្រៃផ្ទៃសរុប ២៩២,៦៩០ហិកតា ទៅឲ្យក្រុមហ៊ុនDisney។

ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិចដែលបង្កឲ្យមានការប្រែប្រួលអាកាសធាតុ។ គម្រោងដែនជម្រកសត្វព្រៃកែវសីម៉ាដែលស្ថិតក្រោមការអនុវត្តន៍គម្រោងរេដបូក (គម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ និងការរេចរឹលនៃព្រៃឈើ) ត្រូវបានបង្កើតឡើងដើម្បីបញ្ចៀសការបញ្ចេញឧស្ម័នកាបូនិចជាង១៤លានតោនសម្រាប់រយៈពេល១០ឆ្នាំនេះ ចន្លោះឆ្នាំ២០១០ ដល់ ២០១៩។

ក្រុមហ៊ុន Disney នឹងប្រើប្រាស់ឥណទានកាបូននេះដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងដើម្បីសម្រេចគោលដៅរបស់ក្រុមហ៊ុន ក្នុងការឈានទៅកាត់បន្ថយការបញ្ចេញឧស្ម័នឲ្យបាន៥០ភាគរយត្រឹមឆ្នាំ២០២០។ ក្រុមហ៊ុន Disney បានប្តេជ្ញាចិត្តវិនិយោគក្នុងវិស័យព្រៃឈើនៅជុំវិញពិភពលោក ពីព្រោះតែប្រយោជន៍ជាច្រើនដែលព្រៃឈើបានផ្តល់ឲ្យ រាប់ចាប់ពីការស្រូបយកកាបូនរហូតដល់ការផ្តល់ជាទីជម្រកដ៏សំខាន់សម្រាប់សត្វព្រៃ។ បន្ថែមពីនេះ ការលក់នេះ ក៏ឆ្លុះបញ្ចាំងអំពីហិរញ្ញប្បទានកាបូន ដែលជួយផ្តល់ជាប្រភពថវិកាប្រកបដោយនិរន្តរភាពមួយសម្រាប់ការអភិរក្សព្រៃឈើតំបន់ត្រូពិចដែលសំបូរដោយទៅដោយប្រភេទសត្វ និងរុក្ខជាតិ ស្ថិតនៅតំបន់ខ្ពស់រាបភាគខាងកើតប្រទេសកម្ពុជ ហើយតំបន់ការពារនេះមានសារៈសំខាន់ជាសាកល។ ការទិញនេះ ក៏ផ្តល់ប្រយោជន៍ដោយផ្ទាល់ផងដែរទៅលើការចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍រស់នៅជុំវិញតំបន់អនុវត្តគម្រោងនេះ។

**លោក John Robinson នាយកផ្នែកអភិរក្ស និងជាអគ្គនាយករងផ្នែកប្រតិបត្តិសម្រាប់ការអភិរក្ស និងវិទ្យាសាស្ត្ររបស់អង្គការ WCS** មានប្រសាសន៍ថា៖ “អង្គការ WCS សូមអបអរសាទរ

ចំពោះរាជរដ្ឋាភិបាលកម្ពុជាចំពោះប្រតិបត្តិការនេះដើម្បីពង្រឹងការងារអភិរក្សនៅកម្ពុជា និងក្រុមហ៊ុន Disney ចំពោះការសម្រេចចិត្តប្រើប្រាស់ឥណទានកាបូនរបស់គម្រោងនេះ ដែលជាជំហានឆ្ពោះមុខមួយដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទាំងកញ្ចក់។ គម្រោងរេដបូកគឺជាយន្តការដ៏សំខាន់មួយដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈការបញ្ចៀសការកាប់បំផ្លាញព្រៃឈើ ហើយសកម្មភាពរបស់រដ្ឋាភិបាល និងវិស័យឯកជន ពិតជាចាំបាច់ខ្លាំងណាស់ដើម្បីអភិរក្សតំបន់ទេសភាពដ៏អស្ចារ្យទាំងអស់នោះ ព្រមទាំងកំណត់ការប្រែប្រួលអាកាសធាតុនៅលើសាកលលោក។ យើងសង្ឃឹមថាក្រុមហ៊ុនផ្សេងទៀត នឹងធ្វើដូចក្រុមហ៊ុន Disney។"

គម្រោងដែនជម្រកសត្វព្រៃកែវសីមា ទទួលបានការគាំទ្រពីគម្រោងគាំទ្រព្រៃឈើ និងជីវចម្រុះរបស់ USAID អនុវត្តដោយអង្គការ Winrock អន្តរជាតិ គម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ និងការរេចរឹលនៃព្រៃឈើរបស់អង្គការសហប្រជាជាតិ(UN-REDD) ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ប្រចាំនៅកម្ពុជា(AFD) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ទីភ្នាក់ងារ NORAD របស់ប្រទេសន័រវែសនិងសហគមន៍អឺរ៉ុប (EU)។

ដែនជម្រកសត្វព្រៃកែវសីមា (អតីតព្រៃការពារសីមា) ផ្តល់ជាទីជម្រកដល់សត្វព្រៃ និងរុក្ខជាតិជាង ៦០ប្រភេទស្ថិតនៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ដែលជាប្រភេទរងការគំរាមកំហែងឈានទៅរកការផុតពូជ។ តំបន់នេះ ក៏មានសារៈសំខាន់ជាសាកលមួយសម្រាប់ការអភិរក្សប្រភេទសត្វពានរ ដូចជាស្វាកន្ទុយស និងទោចថ្ពាល់លឿងជាដើម ពពួកខ្លា ដំរីអាស៊ី ក្រុមគោសាទិស និងសត្វស្លាបជាច្រើនប្រភេទផ្សេងទៀត។ ដែនជម្រកសត្វព្រៃសីមា ក៏ជាផ្តល់ជាលំនៅដ្ឋានសម្រាប់សហគមន៍ជនជាតិដើមភាគតិចព្នងដែលកំពុងរស់នៅ និងពឹងអាស្រ័យលើធនធានព្រៃឈើតំបន់នេះសម្រាប់ សេដ្ឋកិច្ច វប្បធម៌ និងជំនឿសាសនាអស់រយៈពេលជាច្រើនជំនាន់មកហើយ។ ពួកគាត់ក៏ត្រូវបានគិតគូរ និងដាក់បញ្ចូលទៅក្នុងការរៀបចំ និងគ្រប់គ្រងគម្រោងផងដែរ។

ដែនជម្រកសត្វព្រៃកែវសីមា ក៏ដូចជាតំបន់ការពារផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ប្រឈមនឹងបញ្ហាជាច្រើន ដូចជាការកាប់ឈើខុសច្បាប់ និងការកាប់ឆ្ការដីព្រៃដើម្បីធ្វើកសិកម្មទ្រង់ទ្រាយតូច និងទ្រង់ទ្រាយធំដើម្បីដាំកៅស៊ូជាដើម។ គម្រោងមានគោលដៅ កំណត់បញ្ហាធំៗទាំងអស់ នេះដោយពង្រឹងការងារគ្រប់គ្រងតំបន់អភិរក្ស ព្រមទាំងធានាប្លង់កម្មសិទ្ធដីធ្លី និងសិទ្ធិប្រើប្រាស់ធនធានព្រៃឈើសម្រាប់ប្រជាសហគមន៍។ បន្ថែមពីនេះទៀត កញ្ចប់សាច់ប្រាក់ទទួលបាន ៥០ភាគរយពីការលក់ឥណទានកាបូននេះ នឹងផ្តល់ជាប្រយោជន៍ដល់ប្រជាសហគមន៍ តាមរយៈសកម្មភាពផ្សេងៗ ដូចជាគម្រោងអភិវឌ្ឍសហគមន៍ជាដើម។

**ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន** មានប្រសាសន៍ថា៖ "ការលក់ឥណទានកាបូនទ្រង់ទ្រាយធំដំបូងបង្អស់នៅប្រទេសកម្ពុជានេះ គឺជាផ្នែកមួយដ៏សំខាន់នៃចក្ខុវិស័យរបស់យើង ដើម្បីទទួលបាននិរន្តរភាពហិរញ្ញវត្ថុសម្រាប់តំបន់ការពារនៅក្នុងប្រទេសកម្ពុជា។ កិច្ចព្រមព្រៀងដែលយើង បានចុះហត្ថលេខានេះដែលនឹងផ្តល់ថវិកាសឹងតែទាំងអស់សម្រាប់ការការពារព្រៃឈើ និងការអភិវឌ្ឍន៍សហគមន៍ ឆ្លុះបញ្ចាំងអំពីឆន្ទៈរបស់យើងចំពោះការការពារព្រៃឈើ និងប្រជាសហគមន៍នៅកម្ពុជា។"

ឥណទានកាបូនដែលត្រូវបានលក់នេះ ត្រូវបានគេដាក់នៅលើទីផ្សារកាបូនស្ម័គ្រចិត្ត ដែលអាចឲ្យក្រុមហ៊ុនឯកជន អង្គការ និងបុគ្គលម្នាក់ៗ ធ្វើការបង់ប្រាក់សម្រាប់សកម្មភាពជាច្រើនដែលចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នពុល។ នៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ចំនួន និងគុណភាពនៃឥណទានកាបូន ត្រូវបានផ្ទៀងផ្ទាត់ដោយប្រព័ន្ធត្រួតពិនិត្យឈានមុខគេចំនួន០២ គឺស្តង់ដារផ្ទៀងផ្ទាត់កាបូន និងអាកាសធាតុ និងស្តង់ដារសហគមន៍ និងជីវចម្រុះ។

ក្រសួងបរិស្ថាន នឹងរៀបចំពិធីអបអរសាទរមិទ្ធិផលដ៏សំខាន់ចំពោះការងារអភិរក្សព្រៃឈើនៅកម្ពុជាមួយនេះនាពេលខាងមុខនេះ។

**សម្រាប់ព័ត៌មានបន្ថែម៖**

លោក អេង ម៉េងអ៊ី
មន្ត្រីផ្នែកទំនាក់ទំនង
អង្គការសមាគមអភិរក្សសត្វព្រៃនៅកម្ពុជា
ទូរស័ព្ទ៖ ០៧៧ ៧៦ ៥៦ ៧៦
អ៊ីម៉ែល៖ meng@wcs.org